**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃការធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះមានគោលបំណងធ្វើបច្ចុប្បន្នកម្មទិន្នន័យប្រជាជន ពង្រឹងនិងធ្វើឲ្យប្រសើរឡើងនូវការប្រមូល កែច្នៃ និងផ្សព្វផ្សាយទិន្នន័យប្រជាជន ក្នុងរយៈពេលកំណត់មួយនៅក្នុងប្រទេស សម្រាប់អ្នកប្រើប្រាស់ និងអ្នករៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានាក្នុងផែនការអភិវឌ្ឍ។

**មាត្រា២ ..**

អនុក្រឹត្យនេះមានគោលដៅកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨។

**មាត្រា៣ ..**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើប្រជាជនទាំងប្រុស ទាំងស្រី ទាំងក្មេង ទាំងចាស់ ដើម្បីទទួលបាននូវព័ត៌មាន ប្រជាសាស្ត្រដូចជា អាយុ ភេទ ស្ថានភាពអាពាហ៍ពិពាហ៍ និងព័ត៌មានគន្លឹះពីសេដ្ឋកិច្ចគ្រួសារ ការងារ ការអប់រំ និងសុខភាពរបស់ប្រជាជននៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ..**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ជំរឿនប្រជាជន** សំដៅដល់ការរាប់ចំនួនប្រជាជនទាំងប្រុស ទាំងស្រី ទាំងក្មេង ទាំងចាស់ និងទាំងជនជាតិខ្មែរ ទាំងជនបរទេស លើកលែងតែមន្ត្រីអង្គទូតនិងក្រុមជនដូចគ្នានឹងអង្គទូត ដែលកំពុងរស់នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។
- **ប្រជាជន** សំដៅដល់មនុស្សដែលរស់នៅក្នុងប្រទេសណាមួយឬលក្ខណៈសម្គាល់ ប្រជាសាស្ត្រ សង្គម ឬសេដ្ឋកិច្ច ( ភេទ អាយុ ប្រភេទកន្លែងរស់នៅ។ល។)
- **ប្រជាសាស្ត្រ** សំដៅដល់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រអំពីប្រជាជន រួមមានទំហំ សមាសភាព របាយដង់ស៊ីតេ កំណើន និងលក្ខណៈសម្គាល់ផ្សេងៗទៀតរបស់ប្រជាជន ព្រមទាំងហេតុនិងផលវិបាកនៃការប្រែប្រួលកត្តាទាំងនេះ។

## ជំពូកទី២
## កាលបរិច្ឆេទ

**មាត្រា៥ ..**

កំណត់កាលបរិច្ឆេទសម្រាប់ដំណើរការជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា នៅម៉ោងសូន្យ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨។

## ជំពូកទី៣
## យន្តការនិងនីតិវិធី

**មាត្រា៦ ..**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |

ព្រះរាជាណាចក្រកម្ពុជា * ទីស្តីការគណៈរដ្ឋមន្ត្រី *

| | |
|---|---|
| ៤- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| ៥- រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ១រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប | សមាជិក |
| ១៧- រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | សមាជិក |
| ១៨- អនុរដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| ១៩- អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជនត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៧** ..

គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨ មានភារកិច្ចៈ

- ណែនាំនិងអនុម័តរាល់កិច្ចការទូទៅដែលពាក់ព័ន្ធនឹងជំរឿនទូទៅប្រជាជន
- រៀបចំនិងបង្កើតគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននិងគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជន មានទីស្នាក់ការនៅក្រសួងផែនការនិងស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងផែនការ សម្រាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសជំរឿនទូទៅប្រជាជន
- រៀបចំនិងបង្កើតគណៈកម្មាធិការជំរឿនទូទៅប្រជាជនគ្រប់រាជធានីខេត្ត
- តែងតាំងមន្ត្រីឲ្យចូលរួមជំរឿនទូទៅប្រជាជន តាមការស្នើសុំពីគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជន
- ប្រជុំការងារតាមរបបប្រជុំត្រីមាស តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការឬអនុប្រធានគណៈកម្មាធិការ នៅពេលដែលប្រធានគណៈកម្មាធិការអវត្តមាន
- ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីការប្រព្រឹត្តទៅនិងលទ្ធផលនៃជំរឿនទូទៅប្រជាជន។

**មាត្រា៨** ..

គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ។

គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននិងគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជន មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ។

គណៈកម្មាធិការជំរឿនទូទៅប្រជាជនគ្រប់រាជធានីខេត្ត មានសិទ្ធិប្រើប្រាស់ត្រារបស់សាលារាជធានី ខេត្ត។

**មាត្រា៩** ..

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨ ត្រូវមានដំណាក់កាលដូចតទៅ៖

១- កិច្ចប្រតិបត្តិការដំបូងនៃការជំរឿនមាន៖
- ការរៀបចំផែនទី
- ការរាប់និងចុះបញ្ជីលំនៅឋាន
- ការធ្វើអង្កេតនិងជំរឿនសាកល្បង

២- ការធ្វើសម្ភាសន៍សម្រាប់ជំរឿន

៣- កិច្ចប្រតិបត្តិការចុងក្រោយនៃជំរឿនមាន៖
- ការធ្វើអង្កេតសម្រាប់វាយតម្លៃលើជំរឿនដែលបានធ្វើហើយ
- ការធ្វើអង្កេតផ្សេងទៀត ក្នុងករណីចាំបាច់។

**មាត្រា១០ .-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជាអគ្គនាយកជំរឿន ត្រូវមានមន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាលនៃវិទ្យាស្ថានជាតិស្ថិតិនិងមន្ទីរផែនការរាជធានីខេត្ត ជួយរាល់ការងារក្នុងដំណើរការជំរឿន។

**មាត្រា១១ .-**

មន្ត្រីបំពេញការងារជំរឿនរួមមាន អ្នកសម្ភាសស្រង់យកព័ត៌មាន អ្នកត្រួតពិនិត្យ និងភ្នាក់ងារជំនួយការដល់កិច្ចសហប្រតិបត្តិការជំរឿន ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងផែនការ តាមការស្នើសុំរបស់អគ្គនាយកជំរឿន។ ការចាត់ចែងនេះ អនុវត្តបានតែក្នុងកំលុងពេលជំរឿនតែប៉ុណ្ណោះ។

**មាត្រា១២ .-**

រដ្ឋមន្ត្រីក្រសួងផែនការ មានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួងស្ថាប័នសាធារណៈ និងជនសាមញ្ញដើម្បីសហការជួយធ្វើកិច្ចការជំរឿនទូទៅប្រជាជន។

**មាត្រា១៣ .-**

ត្រូវធ្វើជំរឿនជនគ្រប់រូប ដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា វៀរលែងតែសមាជិកអង្គទូតបរទេសនិងក្រុមជនដូចគ្នានឹងអង្គទូតដែរ តាមកិច្ចព្រមព្រៀងដែលត្រូវកំណត់ឡើងជាមួយនឹងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១៤ .-**

ម្ចាស់លំនៅឋានគ្រប់ប្រភេទនិងអ្នកគ្រប់គ្រងទីកន្លែងនានា ត្រូវអនុញ្ញាតឲ្យមន្ត្រីបំពេញការងារជំរឿនបានចូលលំនៅឋានឬទីកន្លែងរបស់ខ្លួន ក្នុងគោលដៅនៃជំរឿន និងអនុញ្ញាតឲ្យមន្ត្រីទាំងនោះបានលាបពណ៌ បិទអក្សរ បិទសញ្ញា ឬលេខសម្គាល់នៅតាមកន្លែងចាំបាច់សម្រាប់បម្រើដល់ការងារជំរឿនទូទៅប្រជាជន។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីក្រសួងផែនការអាចប្រកាសតែងតាំងអ្នកគ្រប់គ្រង តាមទីកន្លែងដែលមានលក្ខណៈពិសេសធ្វើសម្ភាសន៍អ្នកនៅក្នុងរង្វង់គ្រប់គ្រងរបស់ខ្លួន។

អ្នកគ្រប់គ្រងតាមទីកន្លែងពិសេសទាំងនោះមាន៖

ក- មេបញ្ជាការយោធា នគរបាល ដែលគ្រប់គ្រងនៅតាមអង្គភាពប្រមូលផ្តុំ។

ខ- នាយនាវាដែលគ្រប់គ្រងនៅតាមនាវារបស់ខ្លួន។

គ- នាយកមន្ទីរពេទ្យសាធារណៈនិងឯកជន ប្រធានពន្ធនាគារ ប្រធានមណ្ឌលអប់រំកែប្រែ នាយកមជ្ឈមណ្ឌលសង្គ្រោះ នាយកគ្រឹះស្ថានសិក្សា ដែលមានមនុស្សរស់នៅប្រមូលផ្តុំ [illegible] ចៅអធិការវត្ត អ្នកគ្រប់គ្រងវិហារសាសនានានា។

ឃ- អ្នកគ្រប់គ្រងសណ្ឋាគារ អ្នកគ្រប់គ្រងផ្ទះសំណាក់ នាយកមជ្ឈមណ្ឌល [illegible]

ង- អ្នកចាត់ការខ្សែរថភ្លើង អ្នកចាត់ការក្នុងគ្រឹះស្ថានពាណិជ្ជកម្ម អ្នកចាត់ការក្នុង [illegible]

**មាត្រា១៦ ..**

មន្ត្រីដែលគ្មានកាតព្វកិច្ចទទួលខុសត្រូវក្នុងដំណើរការជំរឿន មិនមានសិទ្ធិត្រួតពិនិត្យរាល់សៀវភៅបញ្ជីឬសំណៅកត់ត្រាដែលបានធ្វើឡើងដោយមន្ត្រីបំពេញការងារជំរឿនបានឡើយ។

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា១៧ ..**

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨ មានប្រភពធនធានដូចតទៅ៖

- ថវិកាជាតិ
- ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ
- អំណោយពីសប្បុរសជននានា
- ប្រភពធនធានស្របច្បាប់ផ្សេងៗ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៨ ..**

អនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃការធ្វើជំរឿនមួយនៅទូទាំងប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ ឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ